**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ២១៧.អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅ
# នៃក្រុមប្រឹក្សាសកម្មភាពជនពិការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩១២/០០៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការដែលសរសេរជាអក្សរកាត់ថា **ក.ស.ជ.** ជាយន្តការសម្របសម្រួលថ្នាក់ជាតិនិងពិគ្រោះយោបល់លើបញ្ហាពិការភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## សមាសភាព

**មាត្រា ២.-**

សមាសភាព **ក.ស.ជ.** រួមមាន៖

| | | |
|---|---|---|
| - នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | | ប្រធានកិត្តិយស |
| - រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | ១រូប | អនុប្រធាន |
| - តំណាងអង្គការជនពិការ ដែលជាជនពិការ | ១រូប | អនុប្រធាន |
| - អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងផែនការ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១រូប | សមាជិក |

| | | |
|---|---|---|
| - អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ១រូប | សមាជិក |
| - អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ១រូប | សមាជិក |
| - តំណាងកាកបាទក្រហមកម្ពុជា | ១រូប | សមាជិក |
| - អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១រូប | សមាជិក |
| - អគ្គលេខាធិការរងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ | ១រូប | សមាជិក |
| - អគ្គលេខាធិការរងអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន | ១រូប | សមាជិក |
| - តំណាងអង្គការជនពិការ ដែលជាជនពិការ (បុរស២រូបនិងស្ត្រី២រូប) | ៤រូប | សមាជិក |
| - តំណាងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការក្នុងវិស័យពិការភាព | ១រូប | សមាជិក |
| - តំណាងនិយោជក | ១រូប | សមាជិក |
| - អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្តនីមួយៗ | ១រូប | សមាជិក |
| - អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **ក.ស.ជ.** | | សមាជិកអចិន្ត្រៃយ៍។ |

សមាសភាពជាក់ស្តែងរបស់ **ក.ស.ជ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ ក.ស.ជ.

**មាត្រា ៣.-**

**ក.ស.ជ** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ផ្តល់ការពិគ្រោះយោបល់ជំនាញលើបញ្ហាពិការភាពនិងការស្តារលទ្ធភាពពលកម្ម
- ជួយក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធក្នុងការរៀបចំគោលនយោបាយ ផែនការជាតិ និងយុទ្ធសាស្ត្រ ដែលមានការពាក់ព័ន្ធទៅនឹងពិការភាព និងការស្តារលទ្ធភាពពលកម្ម
- ជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាពនិងការស្តារលទ្ធភាពពលកម្ម
- លើកសំណើកែសម្រួល បំពេញបន្ថែម ធ្វើវិសោធនកម្ម គោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព
- តាមដាន វាយតម្លៃការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនិងបញ្ហាពិការភាព
- ទំនាក់ទំនងជាមួយសហគមន៍ជាតិ អន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធ កៀរគរប្រភពធនធានទាំងក្នុង ទាំងក្រៅប្រទេស
- រៀបចំទិវាជនពិការជាតិ ទិវាជនពិការអន្តរជាតិ និងទិវាជនពិការផ្សេងៗទៀត
- រៀបចំផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពទាក់ទងនឹងពិការភាព
- ដឹកនាំ ចាត់ចែង អនុវត្ត និងធ្វើរបាយការណ៍បូកសរុបលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ
- រៀបចំរបាយការណ៍ស្តីពីស្ថានភាពជនពិការជូនរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ ក.ស.ជ.

**មាត្រា ៤.-**

**ក.ស.ជ.** ត្រូវធ្វើការប្រជុំយ៉ាងតិច២(ពីរ)ដង ក្នុងរយៈពេល១(មួយ)ឆ្នាំ។ ក្នុងករណីចាំបាច់ **ក.ស.ជ.** អាចប្រជុំវិសាមញ្ញបានតាមការអញ្ជើញរបស់ប្រធាន។

**ក.ស.ជ.** ត្រូវធ្វើការបូកសរុបរបាយការណ៍ប្រចាំឆ្នាំអំពីលទ្ធផលនៃការអនុវត្តកម្មវិធីការងារ និងអនុសាសន៍ដែល **ក.ស.ជ.** ត្រូវដាក់ជូនរាជរដ្ឋាភិបាលតាមរយៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ប្រធាន **ក.ស.ជ.** ជាប្រធាននៃរាល់កិច្ចប្រជុំ។ ប្រសិនបើប្រធានអវត្តមាន ប្រធានត្រូវផ្ទេរសិទ្ធិជូនអនុប្រធាន។

**ក.ស.ជ.** អាចអញ្ជើញអ្នកជំនាញពាក់ព័ន្ធឲ្យចូលរួមក្នុងអង្គប្រជុំបាន។

**មាត្រា ៥.-**

**ក.ស.ជ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ននានា តំណាងអង្គការមិនមែនរដ្ឋាភិបាល តំណាងជនពិការដែលជាជនពិការ ដៃគូអភិវឌ្ឍ និងផ្នែកឯកជន ដើម្បីចូលរួមប្រជុំផ្តល់យោបល់ ឬធ្វើជាអ្នកសង្កេតការណ៍តាមការចាំបាច់។

**មាត្រា ៦.-**

របៀបរបបនៃការប្រជុំរបស់ **ក.ស.ជ.** ត្រូវកំណត់ដោយរទបញ្ជាផ្ទៃក្នុងរបស់ **ក.ស.ជ.**។

**មាត្រា ៧.-**

**ក.ស.ជ.** មានសិទ្ធិប្រើត្រាដោយឡែករបស់ខ្លួន ដើម្បីបំពេញការងារ។

**មាត្រា ៨.-**

**ក.ស.ជ.** មានអគ្គលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិ ដែលមានទីតាំងនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា ៩.-**

អគ្គលេខាធិការដ្ឋាន **ក.ស.ជ.** ដឹកនាំដោយអគ្គលេខាធិការមួយរូបនិងមានអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដែលតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

អគ្គលេខាធិការដ្ឋាន **ក.ស.ជ.** មានមន្ត្រីបម្រើការងារមកពីក្របខ័ណ្ឌមុខងារសាធារណៈ ដែលមានស្រាប់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអាចមានទីប្រឹក្សា និងជំនួយការអ្នកជំនាញការជាតិ និងអន្តរជាតិមួយចំនួនតាមការចាំបាច់។

**មាត្រា ១០.-**

**គ.ស.ជ.** អាចបង្កើតគណៈកម្មការឬអនុគណៈកម្មការជំនាញមួយចំនួនតាមការចាំបាច់។ សមាសភាពដឹកនាំរបស់គណៈកម្មការឬអនុគណៈកម្មការនីមួយៗ ត្រូវជ្រើសរើសពីសមាជិកនៃ**គ.ស.ជ.** និងដែលមានមន្ត្រីជំនាញរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ តំណាងជនពិការ តំណាងអង្គការជនពិការ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍចូលរួមជាសមាជិក។

សមាសភាព តួនាទីភារកិច្ចរបស់គណៈកម្មការឬអនុគណៈកម្មការជំនាញ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ស.ជ.**។

## ជំពូកទី៥

## តួនាទីនិងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន គ.ស.ជ.

**មាត្រា ១១.-**

អគ្គលេខាធិការដ្ឋាន **គ.ស.ជ.** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ធានានិរន្តរភាពនិងដំណើរការរដ្ឋបាលរបស់ **គ.ស.ជ.**
- គ្រប់គ្រងមន្ត្រីអគ្គលេខាធិការដ្ឋាន **គ.ស.ជ.**
- លើកសំណើតែងតាំង ផ្ទេរភារកិច្ច បញ្ឈប់ពីតំណែង និងជ្រើសរើសមន្ត្រីរាជការ ជំនួយការ និងបុគ្គលិកក្នុងអគ្គលេខាធិការដ្ឋាន
- លើកគម្រោងថវិកាប្រចាំឆ្នាំសម្រាប់កិច្ចដំណើរការ **គ.ស.ជ.**
- គ្រប់គ្រងអនុវត្ត ចំណូល ចំណាយថវិកា និងបញ្ជីសារពើភណ្ឌ ចលនទ្រព្យ អចលនទ្រព្យរបស់ **គ.ស.ជ.**
- រៀបចំសិក្ខាសាលានិងកិច្ចប្រជុំផ្សេងៗរបស់ **គ.ស.ជ.**
- រៀបចំផ្តល់ការពិគ្រោះយោបល់ជំនាញលើបញ្ហាពិការភាពនិងការស្តារលទ្ធភាពពលកម្ម
- សម្របសម្រួលក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធក្នុងការរៀបចំគោលនយោបាយ ផែនការជាតិ និងយុទ្ធសាស្ត្រ ដែលមានការពាក់ព័ន្ធនឹងពិការភាពនិងការស្តារលទ្ធភាពពលកម្ម
- ជួយជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាពនិងការស្តារលទ្ធភាពពលកម្ម
- រៀបចំការលើកសំណើកែសម្រួល បំពេញបន្ថែម ធ្វើវិសោធនកម្ម គោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព
- ជួយតាមដាន វាយតម្លៃការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព
- សម្របសម្រួលជាមួយសហគមន៍ជាតិ អន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធ គៀរគរប្រភពធនធានទាំងក្នុង ទាំងក្រៅប្រទេស
- រៀបចំទិវាជនពិការជាតិ ទិវាជនពិការអន្តរជាតិ និងទិវាជនពិការផ្សេងៗទៀត
- ធ្វើរបាយការណ៍ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនិងផែនការសកម្មភាពទាក់ទងនឹងពិការភាព

- ជួយសម្របសម្រួលដឹកនាំ ចាត់ចែង អនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការជូនរាជរដ្ឋាភិបាល និងចាត់ចែងបញ្ជូនរបាយការណ៍ទៅអង្គការសហប្រជាជាតិ
- ទទួលនិងអន្តរាគមន៍ដោះស្រាយសំណូមពររបស់ជនពិការ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាពការងារ **ក.ស.ជ.**
- បំពេញភារកិច្ចផ្សេងទៀតដែលប្រធាន **ក.ស.ជ.** ប្រគល់ជូន។

**មាត្រា ១២.-**

អគ្គលេខាធិការដ្ឋាន **ក.ស.ជ.** មានរចនាសម្ព័ន្ធដូចតទៅ៖

១. ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ។

២. ផ្នែកសិទ្ធិជនពិការ។

៣. ផ្នែកសុខុមាលភាពនិងស្តារលទ្ធភាពពលកម្ម។

៤. ផ្នែកសមាហរណកម្មជនពិការ។

៥. ផ្នែកអភិវឌ្ឍសេវាពិការភាព។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន **ក.ស.ជ.** មានភ្ជាប់ជាឧបសម្ព័ន្ធ។

**មាត្រា ១៣.-**

ផ្នែកនីមួយៗដឹកនាំដោយប្រធានផ្នែកមួយរូបមានឋានៈស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានផ្នែកមួយចំនួនដែលមានឋានៈស្មើអនុប្រធាននាយកដ្ឋាន តាមការចាំបាច់។

ផ្នែកនីមួយៗមានការិយាល័យចំណុះតាមការចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា ១៤.-**

ត្រូវបង្កើតក្រុមការងារសកម្មភាពជនពិការ នៅតាមក្រសួង ស្ថាប័ននីមួយៗ និងត្រូវបង្កើតក្រុមប្រឹក្សាសកម្មភាពជនពិការ នៅតាមរាជធានី ខេត្ត។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមការងារសកម្មភាពជនពិការ នៅតាមក្រសួង ស្ថាប័ន និងក្រុមប្រឹក្សា សកម្មភាពជនពិការ ថ្នាក់រាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធាន **ក.ស.ជ.**។

## ជំពូកទី៦
## តួនាទីនិងភារកិច្ចរបស់ផ្នែកនីមួយៗ

**មាត្រា ១៥.-**

ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- អនុវត្តការងាររដ្ឋបាលប្រចាំថ្ងៃរបស់អគ្គលេខាធិការដ្ឋាន

- រៀបចំលិខិតរដ្ឋបាល ធ្វើកំណត់ហេតុរាល់កិច្ចប្រជុំរបស់ **ក.ស.ជ.**
- គ្រប់គ្រងមន្ត្រី បុគ្គលិក និងឯកសាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន
- ធ្វើការបណ្តុះបណ្តាលជំនាញពាក់ព័ន្ធពិការភាព
- រៀបចំគម្រោងថវិកានិងគម្រោងផ្សេងៗទៀត
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ និងបញ្ជីសារពើភណ្ឌរបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងចំណូលនិងចំណាយរបស់អគ្គលេខាធិការដ្ឋាន
- ប្រមូលនិងវិភាគរាល់ទិន្នន័យ ឯកសារពាក់ព័ន្ធនឹងពិការភាព
- សហការជាមួយក្រសួងផែនការក្នុងការធ្វើជំរឿនស្ថិតិជនពិការ
- ចងក្រង បោះពុម្ព និងផ្សព្វផ្សាយឯកសារពាក់ព័ន្ធនឹងពិការភាព
- កសាងជំនាញបច្ចេកទេសទាក់ទងនឹងពិការភាព
- ជួយសម្របសម្រួលជាមួយសហគមន៍ជាតិ អន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធ កៀរគរប្រភពធនធានទាំងក្នុង ទាំងក្រៅប្រទេស
- ទទួលសំណើទាក់ទងនឹងបញ្ហាជនពិការ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន ផ្នែកឯកជន និងសង្គមស៊ីវិល ព្រមទាំងដៃគូអភិវឌ្ឍលើវិស័យពិការភាព
- ធ្វើរបាយការណ៍បូកសរុបប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ របស់អគ្គលេខាធិការដ្ឋាន **ក.ស.ជ.** និងរបស់ **ក.ស.ជ.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **ក.ស.ជ.** ប្រគល់ជូន។

**មាត្រា ១៦.-**

ផ្នែកសិទ្ធិជនពិការ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- សិក្សាស្រាវជ្រាវរាល់លិខិតបទដ្ឋានគតិយុត្តនិងគោលនយោបាយជាតិ ព្រមទាំងអនុសញ្ញាអន្តរជាតិទាក់ទងនឹងជនពិការ ផ្តល់យោបល់លើការអនុវត្តនិងការធ្វើវិសោធនកម្ម
- រៀបចំសេចក្តីព្រាងគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងពិការភាព
- ផ្សព្វផ្សាយគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងពិការភាព
- ជួយជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាពនិងការស្តារលទ្ធភាពពលកម្ម
- ជួយសម្របសម្រួលដឹកនាំ ចាត់ចែង អនុវត្ត អនុសញ្ញាស្តីពីសិទ្ធិជនពិការ
- ស្រាវជ្រាវបូកសរុបវាយតម្លៃធនធានហិរញ្ញវត្ថុសម្រាប់វិស័យពិការភាព
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការជូនរាជរដ្ឋាភិបាល និងចាត់ចែងបញ្ជូនរបាយការណ៍ទៅអង្គការសហប្រជាជាតិ
- ទទួលនិងអន្តរាគមដោះស្រាយសំណូមពររបស់ជនពិការ និងផ្តល់សេវាយុត្តិធម៌ជូនជនពិការ
- សម្របសម្រួលការពិគ្រោះយោបល់លើបញ្ហាពិការភាព
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ប្រព័ន្ធឃោសនា ផ្សព្វផ្សាយសិទ្ធិជនពិការ

- តាមដានការអនុវត្តសិទ្ធិជនពិការ តាមអនុសញ្ញាស្តីពីសិទ្ធិជនពិការនិងច្បាប់ជាធរមាន
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **ក.ស.ជ.** ប្រគល់ជូន។

**មាត្រា ១៧.-**

ផ្នែកសុខុមាលភាពនិងស្តារលទ្ធភាពពលកម្ម មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ស្រាវជ្រាវ រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការសកម្មភាព សម្រាប់ផ្នែកសុខុមាលភាព ស្តារលទ្ធភាពពលកម្មជនពិការ
- ជួយសម្របសម្រួលរៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការសកម្មភាព ស្តីអំពីការបង្ការ ទប់ស្កាត់ពិការភាព
- ជួយសម្របសម្រួលរៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការសកម្មភាព ស្តីពីការស្តារ លទ្ធភាពពលកម្ម ការព្យាបាលដោយចលនា ការព្យាបាលដោយសកម្មភាព ការព្យាបាលដោយការ និយាយ ។ល។
- ជួយសម្របសម្រួលរៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍ សេវាពិសេសដល់ស្ត្រីនិងកុមារពិការ
- ជួយសម្របសម្រួលរៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការសកម្មភាពសម្រាប់ការស្តារ លទ្ធភាពពលកម្ម នៅតាមសហគមន៍សម្រាប់ជនពិការ
- ជួយសម្របសម្រួលរៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការសកម្មភាពអភិវឌ្ឍបច្ចេកវិទ្យា សម្រាប់ការផលិតឧបករណ៍សិប្បនិម្មិតនិងរណប
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំសេចក្តីព្រាងគោលនយោបាយ និងសកម្មភាព សមភាពយេនឌ័ររបស់ស្ត្រីនិងកុមារីពិការ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំសេចក្តីព្រាងគោលនយោបាយ និងសកម្មភាព សម្រាប់សេវាកម្ម និងសមាហរណកម្មកុមារពិការ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **ក.ស.ជ.** ប្រគល់ជូន។

**មាត្រា ១៨.-**

ផ្នែកសមាហរណកម្មជនពិការ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំសេចក្តីព្រាងគោលនយោបាយ និងសកម្មភាព សម្រាប់សមាហរណកម្មជនពិការក្នុងវិស័យអប់រំ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំសេចក្តីព្រាងគោលនយោបាយ និងសកម្មភាព សម្រាប់សមាហរណកម្មជនពិការក្នុងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ និងការផ្តល់ព័ត៌មានទីផ្សារ ការងារសម្រាប់ជនពិការ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំសេចក្តីព្រាងគោលនយោបាយ និងសកម្មភាព សម្រាប់អនុវត្តអត្រាជនពិការចូលបម្រើការងារតាមក្រសួង ស្ថាប័ននិងការអនុវត្តគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍

- សហការជាមួយមូលនិធិជនពិការក្នុងការអភិវឌ្ឍធនធាន សម្រាប់វិស័យពិការភាពនិងស្តារលទ្ធភាពពលកម្ម
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **ក.ស.ជ.** ប្រគល់ជូន។

**មាត្រា ១៩.-**

ផ្នែកអភិវឌ្ឍសេវាពិការភាព មានតួនាទីនិងភារកិច្ចដូចតទៅ៖

- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធក្នុងការរៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការអភិវឌ្ឍបច្ចេកទេសសម្របសម្រួលពិការភាព
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំសេចក្តីព្រាងគោលនយោបាយផែនការសកម្មភាពសម្រាប់ការកែសម្រួលសំណង់អគារ ទីធ្លាសាធារណៈសម្រាប់ការចល័តចេញចូលរបស់ជនពិការ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការសកម្មភាពសម្រាប់កំណត់សមត្ថភាពបើកបរ និងសម្រួលមធ្យោបាយធ្វើដំណើរ ចំណតយានយន្ត បណ្ណបើកបររបស់ជនពិការ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំសេចក្តីព្រាងគោលនយោបាយ និងសកម្មភាពអភិវឌ្ឍភាសាសញ្ញា អក្សរស្ទាប និងបច្ចេកវិទ្យាផ្សេងៗសម្រាប់ពិការភាព
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន នីតិបុគ្គល ក្នុងការអនុវត្តបទដ្ឋានស្តីពីការសម្របសម្រួលសមស្របសម្រាប់ជនពិការ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **ក.ស.ជ.** ប្រគល់ជូន។

## ជំពូកទី៧
## ប្រភពធនធាន

**មាត្រា ២០.-**

ការចំណាយសម្រាប់ដំណើរការរបស់ **ក.ស.ជ.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**ក.ស.ជ.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា ២១.-**

ក្រោយអនុក្រឹត្យនេះចូលជាធរមាន លិខិតបទដ្ឋានគតិយុត្តដែលមានពីមុន ត្រូវបន្តអនុវត្តរហូតដល់លិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា ២២.-**

អនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការរៀបចំសមាសភាពនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ ឧសភា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

ដើម្បីគោរពស្នើសុំហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**អ៊ិត សំហេង**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចមាត្រា២៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៧១៦ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៣**

**អង្គការលេខរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ**

